ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ០៩៩ MOC / SM 2008

# ប្រកាស
## ស្តីពី
## បែបបទ និង នីតិវិធី កែប្រែលក្ខន្តិកៈក្រុមហ៊ុន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦៩៥/ ០៤ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/ ១២ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦០៥/ ០១៩ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងប្រកាសអន្តរក្រសួងលេខ ៦៧៩ សហវ ប្រក . ចមព ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៧ ស្តីពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម
- យោងតាមការចាំបាច់ ក្នុងទិសដៅកែទំរង់វិស័យចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម

Prakas on document requirement for amendment company 2008-04-04/REGTISR/KSH/PHMN/SC

## សំរេច

**ប្រការ ១** : ស្ថាបនិក ឬអភិបាល ឬម្ចាស់ហ៊ុនម្នាក់ៗ ជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តន៍នូវការចុះបញ្ជីពាណិជ្ជកម្ម ការតំកល់ទុក និងការផ្សព្វផ្សាយដែលបានតំរូវដោយច្បាប់ ។

**ប្រការ ២** : ក្រោយការចុះបញ្ជីពាណិជ្ជកម្ម ក្នុងដំណើរការអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុនអាចធ្វើការកែប្រែលក្ខន្តិកៈបានគ្រប់ពេលវេលា ។ ការកែប្រែលក្ខន្តិកៈ អាចធ្វើបានចំពោះ :

ក - ការផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន

ខ - ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬ សកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

គ - ការបែងចែកសាជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ ។

ឃ- ការកែប្រែភាគលាភនៃប្រភេទភាគហ៊ុនណាមួយ ។

ង - ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬ ទាបជាងប្រភេទភាគហ៊ុន ដែលមានរួចហើយ ។

ច - ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតំលៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលបានអនុញ្ញាត ។ ដើមទុនចុះបញ្ជី មិនអាចកាត់បន្ថយអោយនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូងបានឡើយ ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ ការបន្ថយដើមទុនមិនត្រូវហួសពី ៩០ ( កៅសិប ) ថ្ងៃ បន្ទាប់ពីការកែប្រែត្រូវបានកំណត់នៅក្រសួងពាណិជ្ជកម្ម ។ បើក្នុងរយៈពេលនេះ មានការតវ៉ាជំទាស់ពីម្ចាស់បំណុលដែលគ្មានវិវាទជាមួយក្រុមហ៊ុន ម្ចាស់បំណុលនេះត្រូវបានសងប្រាក់ទាំងស្រុង មុនការបន្ថយដើមទុនដែលអាចអនុវត្តទៅបាន ។

ឆ - ការកែប្រែថិរវេលានៃអត្ថិភាពរបស់ក្រុមហ៊ុន ។

ជ - ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី ។

ឈ- ការកែប្រែចំនួនកូរ៉ុម ។

ញ- បន្ថែមបទបញ្ញត្តិណាមួយ ដែលច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អនុញ្ញាតអោយដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

យោងតាមច្បាប់ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន ភាគហ៊ុនទាំងឡាយអាចធ្វើការផ្ទេរបាន ។

**ប្រការ ៣** : រាល់ការកែប្រែ និងការផ្ទេរភាគហ៊ុនដូចមានចែងក្នុងប្រការ២ខាងលើ ត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្មស្របទៅតាមមាត្រា ១៨ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៨៨ / ២១៩ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

ចំពោះការផ្ទេរឬលក់ភាគហ៊ុន ម្ចាស់ហ៊ុនដែលជាអ្នកផ្ទេរឬលក់ភាគហ៊ុនរបស់ខ្លួន ត្រូវមកចុះហត្ថលេខា និងផ្តិតមេដៃដោយផ្ទាល់ នៅចំពោះមុខមន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដើម្បីធានាអះអាង និងទទួលខុសត្រូវលើរាល់សំណុំលិខិតផ្ទេរឬលក់ភាគហ៊ុន ថាពិតជាគ្រប់គ្រាន់និងត្រឹមត្រូវមិនមានក្លែងបន្លំលើប្រការណាមួយឡើយ ។

**ប្រការ ៤ :** កម្រៃរដ្ឋបាលលើបែបបទចេញវិញ្ញាបនប័ត្របញ្ជាក់ការកែប្រែលក្ខន្តិកៈ ត្រូវបានកំនត់ចំនួន ៦០,០០០ រៀល ( ហុកសិបពាន់រៀល ) ស្របតាមប្រកាសអន្តរក្រសួងលេខ ៦៧៩ សហវ ប្រក.ចមព ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៧ ស្តីពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៥ :** សំណុំលិខិតដែលត្រូវផ្តល់ជូន ការិយាល័យត្រួតពិនិត្យអាជីវកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម មានដូចតទៅ :

| | |
|---|---|
| - កំណត់ហេតុ និងសេចក្តីសំរេចសមូហភាពសន្និបាតរបស់ក្រុមហ៊ុន ( មានគំរូស្រាប់ : គំរូ ខ១ B1 ) | ចំនួន ៣ ច្បាប់ |
| - ពាក្យសុំធ្វើការកែប្រែលក្ខន្តិកៈ ( មានគំរូស្រាប់ : គំរូ ខ២ B2 ) | ចំនួន ៣ ច្បាប់ |
| - ពាក្យសុំចុះផ្សាយក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្ម ( មានគំរូស្រាប់ : គំរូខ៣ B3 ) | ចំនួន ៣ ច្បាប់ |
| - វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ចំលង ( មានស្រាប់ ) ( វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ក្នុងករណីក្រុមហ៊ុនធ្វើការកែប្រែនាមករណ៍ ឬប្តូរសញ្ជាតិ ឬប្តូរទ្រង់ទ្រាយក្រុមហ៊ុន ) | ចំនួន ៣ ច្បាប់ |
| - ច្បាប់ចំលងលិខិតគោលការណ៍ទទួលចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ( មានស្រាប់ ) | ចំនួន ៣ ច្បាប់ |
| - ប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្មប្រចាំឆ្នាំ | ចំនួន ១ ច្បាប់ |
| - ច្បាប់ចំលងប័ណ្ណប៉ាតង់ ( មានស្រាប់ ) | ចំនួន ៣ ច្បាប់ |
| - ច្បាប់ចំលងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និង រូបថត ៤ គុណ ៦ របស់ម្ចាស់ហ៊ុនថ្មីម្នាក់ៗ ( ក្នុងករណីមានបន្ថែមសមាជិកភាគហ៊ុនថ្មី ) | ចំនួន ៣ ច្បាប់ |
| - អាជ្ញាប័ណ្ណរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ " បើសិនជាមាន " | ចំនួន ៣ ច្បាប់ |

**ប្រការ ៦ :** នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ត្រូវមានវិធានការសមស្របដើម្បីសហការជាមួយអភិបាលឬម្ចាស់ហ៊ុន ដែលមកសុំធ្វើការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ដើម្បីជួយណែនាំ និង បង្កលក្ខណៈងាយស្រួលដល់ការកែប្រែលក្ខន្តិកៈអោយបានឆាប់រហ័សនិងទាន់ពេលវេលា ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ : (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៨៦
ទូរសារលេខ : (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

**ប្រការ ៧ :** ប្រកាសលេខ ១២០ MOC / SM 2006 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីបែបបទនិងនីតិវិធីកែប្រែលក្ខន្តិកៈក្រុមហ៊ុន របស់ក្រសួងពាណិជ្ជកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨ :** អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋាននីតិកម្ម មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ តាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ.ថ្ងៃទី ០៧..ខែ.០៤..ឆ្នាំ២០០៨

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម_សម្បត្តិ

ចម្លងជូន :

- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី " ជូនជ្រាបជារបាយការណ៍ "
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"
- សាលាខេត្ត-ក្រុង ដើម្បីជួយផ្សព្វផ្សាយ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- ឯកសារ - កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com